00993367

E305/7/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 12 / 06 / 2014
ម៉ោង (Time/Heure) : 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤

**ជូនចំពោះ÷ ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷ លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷ សេចក្តីណែនាំឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ព័ត៌មានបន្ថែមទាក់ទិននឹងការស្នើសុំវិធានការការពារ**

១. នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីដាក់បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានធ្វើបច្ចុប្បន្នភាព ហើយដែលភាគីបានស្នើសុំស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E305) ("ដីកាបង្គាប់រៀបចំសវនាការ")។ ដោយមានការស្នើសុំវិធានការការពារ អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគីកំណត់បុគ្គលដែលពាក់ព័ន្ធ និងចង្អុលបង្ហាញដោយសង្ខេបអំពីការស្នើសុំវិធានការការពារនោះនៅក្នុងបញ្ជីដាច់ដោយឡែកមួយ និងត្រូវដាក់ជាឯកសារ "សម្ងាត់បំផុត" (ឯកសារ E305 កថាខណ្ឌ៥)។

២. នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់បញ្ជីឈ្មោះ សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើសុំនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E305/7)។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានកំណត់បុគ្គលម្នាក់ ដែលខ្លួនបានស្នើសុំវិធានការការពារ នៅក្នុងឧបសម្ព័ន្ធមួយដោយឡែក និងដាក់ជាឯកសារ "សម្ងាត់បំផុត" (ឯកសារ E305/7.1.2)។ ប៉ុន្តែ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីខកខានពុំបានចង្អុលបង្ហាញអំពីវិធានការការពារ ដែលខ្លួនបានស្នើសុំ ឬបញ្ជាក់មូលហេតុនៃការខកខាននេះឡើយ។ ប្រការនេះគឺជាការខកខានមិនបានអនុវត្តទៅតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ ដែលអង្គជំនុំជម្រះមានភារកិច្ចក្នុងការធានាថាសវនាការធ្វើឡើង ដោយគោរពយ៉ាងពេញលេញដល់ការការពារចំពោះជនរងគ្រោះ (មាត្រា ៣៣(ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៣ នៃកិច្ចព្រមព្រៀង)។ ហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ឱ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីកំណត់បង្ហាញនូវវិធានការការពារដែលបានស្នើសុំក្នុងលក្ខណៈ "សម្ងាត់បំផុត" នៅត្រឹម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤។

៣. អង្គជំនុំជម្រះនឹងស្នើសុំភាគីដាក់សារណាបន្ថែមទៀត ទាក់ទិននឹងសំណើសុំវិធានការការពារទាំងនេះ ទៅតាមពេលវេលាសមស្រប (ឯកសារ E305 កថាខណ្ឌ ៦)។